ISSN 1560-7615 / ISBN 978-99950-52-06-5

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៦ លេខ ២ មេសា - មិថុនា ឆ្នាំ២០១២ តម្លៃ ១.៥០០៛

# នគរូបនីយកម្មនៅកម្ពុជា៖ និន្នាការសំខាន់ៗ និង អាទិភាពគោលនយោបាយ[១]

លោក Ban Ki-moon អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ បាននិយាយថា មនុស្សជាតិ បានឈានចូលដល់សតវត្សរ៍នៃទីក្រុងហើយ។ ប្រជាជនលើពិភពលោកជាង ៥០% រស់នៅក្នុងតំបន់ទីក្រុង។ តាមការប៉ាន់ស្មាន តួលេខអ្នករស់នៅតំបន់ទីក្រុងនៅអាស៊ីអាគ្នេយ៍ នឹងកើនដល់ ៧៣% នៅឆ្នាំ២០៥០ (UN-HABITAT 2008: 12)។ ការផ្លាស់ប្តូរយ៉ាងគំហុក នៃកន្លែងរស់នៅរបស់មនុស្សនេះ ផុសចេញពីកំណើនសារៈសំខាន់នៃទីក្រុង ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចពិភពលោក។ កន្លែងទីក្រុង ជាចំណុចស្នូលនៃឧស្សាហកម្ម ហើយបណ្តាញទីក្រុង គឺជាប្រព័ន្ធខួរក្បាលនៃសេដ្ឋកិច្ចពិភពលោក។ លំហទីក្រុងនៅកម្ពុជា ជាច្រកចេញចូលកាន់តែសំខាន់ឡើង ទៅកាន់បណ្តាញសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក ដែលសំខាន់បំផុតក្នុងការជួយសម្រួលវិនិយោគ និងពាណិជ្ជកម្មឆ្លងកាត់ប្រទេស។ តំបន់ទីក្រុងនៅកម្ពុជា មានប្រជាជនកើនឡើងយ៉ាងលឿន ក្នុងអត្រាប្រចាំឆ្នាំជាមធ្យម ៤,៣៤% ពីឆ្នាំ២០០០ ដល់ ២០១០ (World Bank 2012)។ ពិតមែនតែនគរូបនីយកម្មតែងផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍ វាក៏តែងមានវិសមភាព និងភាពខ្វះខាតផងដែរ ហើយកម្ពុជាដែលស្ថិតក្នុងចំណោមប្រទេសមាន អត្រាភាពក្រីក្រនៅទីក្រុងកម្រិតខ្ពស់បំផុតនៅក្នុងតំបន់ ក៏ជួបបញ្ហានេះដែរ។ អន្តរាគមន៍ទាន់ពេលវេលារបស់រដ្ឋាភិបាល គឺចាំបាច់បំផុត ដើម្បីញ៉ាំងឲ្យនគរូបនីយកម្មវាបម្រើឲ្យគ្រប់គ្នា មានចីរភាព អាចហុចផលចំណេញបានច្រើនបំផុត និងបានទៅដល់គ្រប់ស្រទាប់សង្គម។ ដោយផ្អែកលើទស្សនៈខាងលើ ឯកសារនេះពិនិត្យពីតួនាទីនៃតំបន់ទីក្រុងក្នុងការអភិវឌ្ឍប្រទេសកម្ពុជា ធ្វើការវាយតម្លៃពីបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងកំណើនតំបន់ទីក្រុងទៅថ្ងៃខាងមុខ ព្រមទាំងកំណត់ពីគោលនយោបាយសំខាន់ៗដែលត្រូវមាន ដើម្បីដោះស្រាយបញ្ហាទាំងនោះ។ នៅផ្នែកខាងចុងនៃឯកសារនេះ មានការគូសបញ្ជាក់ពីកំណើនតម្រូវការកម្មវិធីស្រាវជ្រាវដ៏សកម្មមួយ ពីតំបន់ទីក្រុង ដើម្បីផ្តល់ជាព័ត៌មានឲ្យបានគ្រប់គ្រាន់ដល់ការកសាងគោលនយោបាយតំបន់ទីក្រុងនៅពេលអនាគត។



*ទីក្រុងនៅប្រទេសកម្ពុជា បានរីកលូតលាស់យ៉ាងលឿន ក្នុងពីរទសវត្សរ៍ចុងក្រោយនេះ៖ ភ្នំពេញ ខែឧសភា ឆ្នាំ២០១២។*

## តំបន់ទីក្រុងនៅកម្ពុជា

តាំងពីយូរលង់មកហើយគេតែងយល់ថា តំបន់ទីក្រុងជាកន្លែងដែលមនុស្ស ធ្វើការទាក់ទងគ្នា រៀនសូត្រ ច្នៃប្រឌិត និងរីកចម្រើនឡើង គឺតាំងពីទីក្រុងនៅប្រទេសក្រិចដែលជាទីកំណើតនៃលទ្ធិប្រជាធិបតេយ្យ រហូតដល់ទីក្រុងនៅប្រទេសអង់គ្លេស

## មាតិកា

នគរូបនីយកម្មនៅកម្ពុជា៖ និន្នាការសំខាន់ៗ និងអាទិភាព គោលនយោបាយ ..................................... ១
មូលធនសង្គមក្នុងសហគមន៍នៅតំបន់ទីក្រុង និងជនបទនៅ កម្ពុជា ..................................... ៦
អភិបាលកិច្ចទីប្រជុំជនក្នុងបរិបទវិមជ្ឈការនៅកម្ពុជា៖ ប្រធានបទមិនសូវមានគេស្រាវជ្រាវ? ..................... ១១
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ..................... ១៥
— ស្ថានភាពក្នុងប្រទេស ..................... ១៧
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ..................... ២៤

---

១ អត្ថបទនេះរៀបរៀងដោយលោក B. C. R. Flower ជានិស្សិតថ្នាក់បណ្ឌិតនៃសាកលវិទ្យាល័យ UCL និងជាកម្មសិក្សាការីផ្នែកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

នៅសតវត្សរ៍ទី១៩ ដែលនៅទីនោះប្រព័ន្ធឧស្សាហកម្មបាន រីងប៉ឹងឡើង ឆ្លងតាមការបង្កើតរោងចក្រស្លដែក និងការនាំចេញ ទៅទូទាំងពិភពលោក។ ទីក្រុងបង្ហាញឲ្យឃើញជាក់ស្ដែងថា សង្គមវាយ៉ាងដូចម្ដេចកាលពីមុន នៅពេលនេះ និងទៅអនាគត ចង់ក្លាយជាអ្វី។ ក្នុងប្រវត្តិសាស្ត្រកម្ពុជា ទីក្រុងជាកន្លែងដែលរដ្ឋ និងសង្គម បានព្យាយាមកសាងចក្ខុវិស័យរបស់ខ្លួនអំពី ពិភពលោក។ រដ្ឋបាលអាណានិគម បានព្យាយាមកសាងអារ្យធម៌ តំបន់ទីក្រុង តាមរយៈការសាងសង់អគារធំៗ ការរៀបចំកម្មសិទ្ធិ ដីធ្លីដោយដាក់អនុវត្តប្រព័ន្ធសិទ្ធិកាន់កាប់ដីធ្លីបែបអឺរ៉ុប និងការ កសាងហេដ្ឋារចនាសម្ព័ន្ធទំនើបៗដើម្បីសម្រួលដល់ពាណិជ្ជកម្ម។ ក្រុងបាត់ដំបង និងភ្នំពេញ ត្រូវបានអភិវឌ្ឍជាមជ្ឈមណ្ឌល សេដ្ឋកិច្ចដែលតភ្ជាប់ផលិតកម្មកសិកម្ម (ក្នុងទម្រង់ជាដីសម្បទាន គ្រប់គ្រងដោយបារាំង) ទៅទីផ្សារក្នុងតំបន់ និងក្នុងពិភពលោក។ នៅក្រោយរបបអាណានិគម ទីក្រុងនៅកម្ពុជាបានតំណាងឲ្យ សម័យកាលថ្មីមួយនៃទីក្រុងខ្មែរ។ គំនិតជាតិនិយម បានជ្រាប ចូលទៅក្នុងការកសាងទីក្រុង តាមរយៈស្ថាបត្យករខ្មែរឈានមុខ មួយក្រុម ដែលមានលោក វណ្ណ មូលីវណ្ណ ជាចម្បង។ សាកលវិទ្យាល័យ វិមានឯករាជ្យ ក្រសួង និងបណ្ណាល័យជាច្រើន ត្រូវបានកសាងឡើងយ៉ាងលឿន ដើម្បីព្យាយាមប្រែក្លាយទីក្រុង និងអនាគតរបស់កម្ពុជា ឲ្យទៅជារបស់ខ្មែរវិញ។ យុគសម័យ ដ៏ភ្លឺត្រចះនៃនគរូបនីយកម្មនៅកម្ពុជានេះ បានស្ទះដំណើរទៅវិញ ដោយសារសង្គ្រាមស៊ីវិលមួយ ដែលបាននាំមកនូវការអនុវត្ត មនោគមវិជ្ជាដ៏ឃោរឃៅបំផុតនៅក្នុងបរិស្ថានទីក្រុង ពោលគឺ គោលគំនិតប្រឆាំងទីក្រុងរបស់ពួកខ្មែរក្រហម ដែលបានសម្លាប់ រង្គាលប្រជាជននៅទីក្រុង និងបញ្ឈប់ដំណើរការនគរូបនីយកម្ម។ នាបច្ចុប្បន្ន គេបាននិងកំពុងរៀបចំទីក្រុងជាថ្មីម្ដងទៀត ទុកជា កន្លែងនាំមុខគេក្នុងការអភិវឌ្ឍប្រទេស។ ទីក្រុងនេះ ក៏ជាកន្លែង មួយដែលមូលធននិយមពិភពលោក វាស្ដែងចេញក្រោមរូបភាព ជាដំណើរការផ្នែកវប្បធម៌ និងសេដ្ឋកិច្ចសង្គមកិច្ចផ្សារភ្ជាប់នឹង មូលដ្ឋានច្រើនបែបយ៉ាង។

ទីក្រុងដែលតំណាងឲ្យបណ្ដាញក្នុងតំបន់ និងក្នុងពិភព លោកនោះ បានក្លាយជាចំណុចស្នូលនៃគំរូកំណើនសេដ្ឋកិច្ច របស់កម្ពុជាក្នុងរយៈពីរទសវត្សរ៍កន្លងមកនេះ។ មូលធនបរទេស បានដើរតួនាទីស្នូលក្នុងការជំរុញឧស្សាហកម្មកាត់ដេរ សំណង់ និងទេសចរណ៍ ដែលជាមូលដ្ឋានគ្រឹះសម្រាប់កំណើនសេដ្ឋកិច្ច កម្ពុជា។ បើសម្លឹងទៅអនាគត មជ្ឈមណ្ឌលទីក្រុងនឹងដើរតួនាទី សំខាន់បំផុត ដើម្បីសម្រេចឲ្យបានតាមចក្ខុវិស័យរបស់រដ្ឋនៃការ ធ្វើពិពិធកម្មសេដ្ឋកិច្ចចេញពីវិស័យស្នូលមួយចំនួនតូច ឆ្ពោះទៅ កាន់ផលិតផលថ្មីៗទៀតនៃ កម្មន្តសាលកម្ម សេវាកម្ម និង កសិកម្ម និងចក្ខុវិស័យនៃការចាក់ឫសចូលយ៉ាងជ្រៅទៅក្នុង បណ្ដាញសេដ្ឋកិច្ចក្នុងតំបន់។ប៉ុន្តែរដ្ឋាភិបាលត្រូវបង្កើនសមត្ថភាព ទាំងខាងហេដ្ឋារចនាសម្ព័ន្ធរឹង (ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត) និងទន់ (ក្របខ័ណ្ឌច្បាប់) ប្រសិនបើចង់ឲ្យតំបន់ទីក្រុងកម្ពុជា ជាពិសេស ទីក្រុងភ្នំពេញ អាចជួយឲ្យចក្ខុវិស័យខាងលើក្លាយជាការពិត។ ចំពោះហេដ្ឋារចនាសម្ព័ន្ធទន់ ការប្រកាសប្រើក្របខ័ណ្ឌច្បាប់ និង បទបញ្ញត្តិដែលរលូនគ្នាល្អជាមួយប្រទេសឯទៀតក្នុងតំបន់ និង ពិភពលោក ដូចជា កំណែទម្រង់ជាច្រើនស្របតាមផែនទីបង្ហាញ ផ្លូវឆ្នាំ២០១៥ របស់សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) បានរួមចំណែកច្រើនណាស់ ក្នុងការជួយឲ្យតំបន់ទីក្រុងទទួល បានផលចំណេញពីវិនិយោគផ្ទាល់ពីបរទេស សមាហរណកម្ម ចូលទៅក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ក្នុងតំបន់ និងការផ្លាស់ប្ដូរចំណេះដឹង ជាមួយក្រុមហ៊ុនពហុជាតិ ស្ថាប័នស្រាវជ្រាវ និងបណ្ដាញ ពាក់ព័ន្ធនានា។ ទោះយ៉ាងនេះក្ដី ក៏នៅមានបញ្ហាច្រើនទៀតខាង សមត្ថភាពស្ថាប័ន ដែលកំពុងរារាំងដល់ការធ្វើសមាហរណកម្ម ស៊ីជម្រៅនាពេលសព្វថ្ងៃ។ ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋាភិបាល បានប្ដេជ្ញាចិត្តធ្វើកំណែទម្រង់បណ្ដាស្ថាប័ននៅទន់ខ្សោយ ដូចជា ប្រព័ន្ធតុលាការជាដើម ព្រមទាំងបង្កើតរចនាសម្ព័ន្ធតាមស្តង់ដារ ពិភពលោកថ្មីៗ ដែលមានតម្លាភាព និងគណនេយ្យភាព (ឧ. ក្រុមប្រឹក្សាអាជ្ញាកណ្ដាល) ដើម្បីបំបាត់ការចែកចាយមិនស្មើភាព នូវព័ត៌មានទីផ្សារដែលកំពុងរារាំងដល់ពាណិជ្ជកម្ម និងវិនិយោគ។

ដើម្បីទាញយកអត្ថប្រយោជន៍បានច្រើនបំផុត ពីទំនាក់ទំនង តភ្ជាប់គ្នាក្នុងតំបន់ និងក្នុងពិភពលោកនោះ ការកសាងស្ថាប័ន និង កំណែទម្រង់បទបញ្ញត្តិ ត្រូវបំពេញឲ្យគ្នាទៅវិញទៅមក និងត្រូវ មានការកែលំអហេដ្ឋារចនាសម្ព័ន្ធរឹង ឲ្យបានសមស្របផង។ Harvey (2004) លើកថា ទីក្រុងគឺជាសមាសភាគដ៏សំខាន់បំផុត មួយនៃលទ្ធិមូលធននិយម ដើម្បីព្យាយាមបំបាត់ចម្ងាយ និង គម្លាតពេល រវាងផលិតផល និងទីផ្សារ។ ដើម្បីបំពេញមុខងារនេះ ត្រូវមានការរីកចម្រើនធំៗខាងទូរគមនាគមន៍ ដឹកជញ្ជូន និង សមត្ថភាពផ្នែកផ្គត់ផ្គង់ (logisticalcapacity) ហើយជាថ្មីម្ដងទៀត តំបន់ដែលត្រូវផ្ដោតការយកចិត្តទុកដាក់ភ្លាមៗ គឺ ទីក្រុងភ្នំពេញ។ អន្តរាគមន៍គោលនយោបាយខាងផ្នែកនេះ អាចកាត់បន្ថយ ចំណាយផលិតកម្ម ជួយប៉ះប៉ូវដល់កំណើនចំណាយបៀវត្សរ៍ និងជំរុញវិនិយោគ។ មជ្ឈមណ្ឌលទីក្រុង ដែលមានហេដ្ឋា រចនាសម្ព័ន្ធតាមស្តង់ដារពិភពលោក ក៏នឹងជួយសម្រួលដល់ ការអភិវឌ្ឍកសិកម្មដែរ តាមការកាត់បន្ថយចម្ងាយរវាងស្រែចំការ នៅខេត្តបាត់ដំបង និងកន្លែងហូបចុកនៅក្រុង ភ្នំពេញ បាងកក ឬស៊ីដនី។ រដ្ឋាភិបាល ដោយមានជំនួយគាំទ្រពីដៃគូ អភិវឌ្ឍន៍នានា បាននិងកំពុងចូលរួមយ៉ាងសកម្មក្នុងការងារនេះ។ កន្លងមក មានការបង្កើតកម្មវិធីជាច្រើនសម្រាប់ពង្រីកទំនាក់ទំនង តភ្ជាប់គ្នាក្នុងតំបន់ នៅក្រោមគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ នៅមហាអនុតំបន់មេគង្គ ដែលទ្រទ្រង់ដោយធនាគារអភិវឌ្ឍន៍ អាស៊ី (ADB)។ ម្យ៉ាងទៀត ក៏ត្រូវគិតគូរជាសំខាន់ដែរពីតម្រូវការ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈទៅអនាគត ដោយមានធ្វើផែនការ អភិវឌ្ឍន៍ទីក្រុងដ៏សមស្រប ជាពិសេសការរក្សាតុល្យភាពរវាង សេវាសាធារណៈ និងការអភិវឌ្ឍវិស័យឯកជន។ នាបច្ចុប្បន្ន រដ្ឋាភិបាលកំពុងបង្កើតផែនការមេសម្រាប់ទីក្រុងភ្នំពេញ ហើយ ទៅអនាគតទើបឃើញច្បាស់ពីឥទ្ធិពលនៃផែនការនេះ។

## ការអភិវឌ្ឍទីក្រុងសម្រាប់គ្រប់គ្នា

ភាពក្រីក្រនៅទីក្រុង គឺជាទិដ្ឋភាពលេចធ្លោ និងគួរឲ្យបារម្ភ ខ្លាំងមួយនៃនគរូបនីយកម្មនៅកម្ពុជា។ នាបច្ចុប្បន្ន កន្លែងស្នាក់នៅ យ៉ាប់យ៉ឺន អសន្តិសុខក្នុងការកាន់កាប់ និងអវត្តមានយន្តការ

រូបភាព ១៖ ប្រេវ៉ាឡង់នៃអ្នករស់នៅក្នុងសង្កាត់តោកយ៉ាក[២] នៅតាមប្រទេសអាស៊ីអាគ្នេយ៍




*ប្រភព៖ UN-HABITAT ( 2008: 180 )*

ទ្រទ្រង់សង្គមគ្រប់គ្រងដោយរដ្ឋ ជាកត្តាចម្បងដែលបង្ក និងរក្សាអត្រាភាពក្រីក្រនៅតាមទីក្រុងកម្ពុជា ឲ្យស្ថិតក្នុងចំណោមតួលេខខ្ពស់ៗបំផុតក្នុងតំបន់ (រូបភាព ១)។ ប្រសិនបើមិនមានអន្តរាគមន៍ខាងគោលនយោបាយទេនោះ បញ្ហានឹងចោទកាន់តែខ្លាំងឡើងទៀតក្នុងប៉ុន្មានឆ្នាំទៅមុខ។ គេព្យាករថា ពីឆ្នាំ២០០៥ ដល់ ២០១២ ប្រជាជននៅទីក្រុងភ្នំពេញ នឹងកើនឡើងមួយជាពីរ ដល់ ២,៩១លាននាក់ ( UN-HABITAT 2008: 167 ) ហើយប្រជាជនក្រីក្រនៅទីក្រុង នឹងមានចំណែកយ៉ាងធំក្នុងកំណើននេះ។ ប្រសិនបើរដ្ឋាភិបាលមិនធ្វើសកម្មភាពនៅពេលនេះ ដើម្បីអនុវត្តគោលនយោបាយជំរុញឲ្យការរីកចម្រើន ខាងសេដ្ឋកិច្ច និងសង្គមមានលក្ខណៈរាប់បញ្ចូល ពោលគឺ អត្ថប្រយោជន៍នៃកំណើននឹងចែកចាយទៅដល់គ្រប់ស្រទាប់សង្គម និងញ៉ាំងឲ្យនិន្នាការអភិវឌ្ឍន៍ទីក្រុងនៅកម្ពុជា វាមានសមធម៌ និងនិរន្តរភាពនោះទេ ស្ថិរភាពសេដ្ឋកិច្ច និងសង្គមនាពេលអនាគត ពិតជានឹងមានការប៉ះពាល់ធ្ងន់ធ្ងរ។

ប្រវត្តិសាស្ត្របង្ហាញថា ចម្លើយតបរបស់រដ្ឋាភិបាលចំពោះភាពក្រីក្រនៅតំបន់ទីក្រុង អាចបែងចែកជាពីរប្រភេទធំៗ គឺ៖ ១) ចាត់វិធានការសម្រាលភាពក្រីក្រ និងដាក់បញ្ចូលជនក្រីក្រទៅក្នុងរចនាសម្ព័ន្ធទីក្រុង និង ២) ញែកពួកគេចេញពីពិភពទីក្រុង ហើយចាត់ទុកជាក្រុមអន់ថយមួយ ឬជាករណីមិនប្រក្រតីមួយនៃការអភិវឌ្ឍ។ ការផ្លាស់ប្តូរពីគោលនយោបាយនគរូបនីយកម្មប្រឆាំងជនក្រីក្រ ទៅជាគោលនយោបាយនគរូបនីយកម្មគាំទ្រជនក្រីក្រ ត្រូវផ្អែកជាសំខាន់លើការយល់ឃើញរបស់រដ្ឋ និងសង្គម ចំពោះភាពក្រីក្រនៅទីក្រុង ហើយរឿងនេះមួយចំណែកស្ថិតលើការផ្លាស់ប្តូរក្នុងការនិយាយស្តី និងឥរិយាបថផ្អែកវប្បធម៌។ តួយ៉ាង ក្នុងអំឡុងបដិវត្តន៍ឧស្សាហកម្មនៅប្រទេសអង់គ្លេស ទាំងរដ្ឋាភិបាល និងប្រជាជនដែលមានសិទ្ធិបោះឆ្នោតភាគច្រើន ដើមឡើយយល់ឃើញថា ជនក្រីក្រនៅទីក្រុងជា "មនុស្សចម្លែក គ្មានសមត្ថភាព គំរាមកំហែងគេ អសីលធម៌ ដែលតាំងពីដើមរៀងមក រដ្ឋតែងមានគោលនយោបាយភាពក្រីក្រប្រឆាំងនឹងពួកនេះ" ( Moore & Putzel 1999: 23 )។ រហូតមកដល់លោក Charles Booth ដែលបានលើកទស្សនៈស្តីពី "ជនក្រីក្រដែលគួរជួយ" ( deserving poor ) ( ដែលផ្ទុយពីទស្សនៈជនក្រីក្រមិនគួរជួយ" ) ទើបមានការវែកញែកពីវណ្ណៈនៃអ្នកខំធ្វើការដែលគួរទទួលបានការជួយទ្រទ្រង់ ហើយយទស្សនៈនេះធ្វើឲ្យមានការផ្លាស់ប្តូរគោលនយោបាយផាត់ចេញ ប្រឆាំងនឹងជនក្រីក្រ ទៅជាគោលនយោបាយរាប់បញ្ចូល ដើម្បីប្រឆាំងនឹងភាពក្រីក្រ។ ការផ្លាស់ប្តូរផ្នែកវប្បធម៌នេះ បានត្រួសត្រាយផ្លូវសម្រាប់គោលនយោបាយសុខមាលភាពសង្គមសម្រាប់គ្រប់គ្នាទាំងអស់ ដូចជាការធានារ៉ាប់រងរបស់ជាតិជាដើម។ តាំងពីដើមរៀងមកនៅកម្ពុជា ការយល់ឃើញជាទូទៅពីជនក្រីក្រនៅទីក្រុង មិនសូវជំរុញឲ្យមានគោលនយោបាយនគរូបនីយកម្មគាំទ្រជនក្រីក្រឡើយ។ ឯកសារយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រចុងក្រោយបំផុត របស់កម្ពុជា ( RGC 2002: 85-86 ) បានកត់សំគាល់ថា៖

> *ទាំងអាជ្ញាធរ និងអ្នកធូរធារដែលរស់នៅទីក្រុង ច្រើនតែដាក់កំហុសលើជនក្រីក្រ ចំពោះស្ថានភាពដ៏លំបាករបស់ពួកគេ និងចាត់ទុកជនក្រីក្រ ថាជា មនុស្សបង្កគ្រោះថ្នាក់ដល់សង្គម ចូលចិត្តប្រព្រឹត្តអំពើមានទោស ឬក៏មានបញ្ហាខាងខួរក្បាលទៀតផង។ ចម្លើយតបទូទៅពីប្រជាជនថ្នាក់កណ្តាល និងមន្ត្រីនានា គឺជនក្រីក្រនៅទីក្រុង គួរតែបញ្ជូនទៅតំបន់ជនបទដែលពួកគេធ្លាប់រស់នៅនោះវិញ។*

ចំណុចនេះ អាចពិនិត្យឃើញក្នុងគោលនយោបាយផាត់ចេញផ្សេងៗ ដូចជា ការបណ្តេញ និងផ្លាស់ប្តូរកន្លែងទីតាំងសហគមន៍ក្រីក្រនៅទីក្រុង ជាដើម។

នាបច្ចុប្បន្នមានមានសញ្ញាបង្ហាញថា ការយល់ឃើញអវិជ្ជមានពីជនក្រីក្រនៅទីក្រុង អាចកំពុងផ្លាស់ប្តូរ ដោយសារជាសំខាន់ សកម្មភាពបែបថ្មីរបស់អង្គការសង្គមស៊ីវិល ដូចជា មូលនិធិអភិវឌ្ឍន៍ជនក្រីក្រនៅទីក្រុង ( UPDF )[៣] ជាដើម។ UPDF ជួយជនក្រីក្រកែលំអកន្លែងតាំងលំនៅ តាមរយៈគម្រោងហេដ្ឋារចនាសម្ព័ន្ធដឹកនាំដោយសហគមន៍ ដោយបានផ្តល់ប្រាក់កម្ចីដល់ជនក្រីក្រ និងជំរុញការចូលរួម និងកិច្ចសហការរវាងសហគមន៍ក្រីក្រ រដ្ឋាភិបាល និងវិស័យឯកជន ដើម្បីព្យាយាមដោះស្រាយបញ្ហាផ្សេងៗ ដូចជា លក្ខខណ្ឌរស់នៅគ្មានអនាម័យ

---

[២] UN-HABITAT ( 2008: 33 ) ឲ្យនិយមន័យគ្រួសារនៅសង្កាត់តោកយ៉ាកថាជាបុគ្គល ឬមនុស្សមួយក្រុម ដែលរស់នៅក្រោមដំបូលផ្ទះតែមួយ នៅក្នុងតំបន់ទីក្រុង ហើយខ្វះខាតគ្រឿងសម្រួលការមួយ ឬច្រើន ក្នុងចំណោមប្រាំមុខដូចតទៅ៖ ផ្ទះជាប់លាប់ កន្លែងរស់នៅមានទំហំគ្រប់គ្រាន់ លទ្ធភាពប្រើប្រាស់ទឹកបានកែលំអគុណភាព លទ្ធភាពប្រើសេវាអនាម័យបានកែលំអគុណភាព និងការកាន់កាប់មានសន្តិសុខ។ ដោយសារនៅតាមប្រទេសភាគច្រើន គេមិនអាចរកបានព័ត៌មានស្តីពី ការកាន់កាប់មានសន្តិសុខ ដូច្នេះមានតែសូចនាករបួនខាងដើមប៉ុណ្ណោះ ដែលបានយកមកប្រើដើម្បីកំណត់និយមន័យគ្រួសារនៅសង្កាត់តោកយ៉ាក។

[៣] មាន NGOs នៅទីក្រុងជាច្រើនទៀត ដែលបាននិងកំពុងធ្វើការងារដើម្បីផ្តល់សិទ្ធិអំណាចដល់ជនក្រីក្រនៅទីក្រុង ជាអាទិ៍ ក្រុមការងារផ្នែកទីក្រុង ( USG ) ( បច្ចុប្បន្ន បានរំសាយហើយ ) និងអង្គការអភិវឌ្ឍស្ត្រីក្រីក្រនៅទីក្រុង ( UPWD ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៧ និងទ្រទ្រង់ដោយ អង្គការ ActionAid International-Cambodia ) ជាដើម។ UPDF បង្កើតឡើងនៅឆ្នាំ១៩៩៨។

ការកាន់កាប់គ្មានសន្តិសុខ និងកង្វះហេដ្ឋារចនាសម្ព័ន្ធសេវាកម្ម (e.g. Phonphakdee *et al.* 2009)។ នៅឆ្នាំ២០០៩ UPDF ជួយទ្រទ្រង់ក្រុមសន្សំប្រាក់បានដល់ ២០០០ក្រុម (ក្នុង ២៦ក្រុង) ដែលមានសមាជិក ២៤.០០០នាក់ និងអះអាងថា សន្សំប្រាក់បានលើសពី ៧០០.០០០ដុល្លារ ដូច្នេះបើគិតចាប់ពីពេលកកើតឡើង មូលនិធិនេះផ្តល់កម្ចីបានជាង ២.០០០.០០០ដុល្លារ ទៅឲ្យសហគមន៍ក្រីក្រនៅទីក្រុង (Mitlin *et al.* 2011:37)។ UPDF បានជួយសម្រួលសកម្មភាពសមូហភាពរបស់ប្រជាជនសាមញ្ញ ដែលកែលំអផលប៉ះពាល់របស់ជនក្រីក្រទៅលើទីក្រុង ទាំងផ្នែកសោភ័ណភាព និងផ្នែកសេដ្ឋកិច្ចសង្គមកិច្ច។ តាមសកម្មភាពនេះ UPDF បានទប់ទល់នឹងគំនិតចាក់ឫសតាំងពីដើម ដែលថា អ្នកក្រជាមនុស្សខ្ជិល និងជាដើមហេតុនៃភាពក្រីក្ររបស់ខ្លួន។ UPDF ក៏បានជំរុញការតភ្ជាប់រវាង អង្គការជនក្រីក្រនៅទីក្រុង និងរដ្ឋាភិបាល ហើយតាមនេះ បានបង្កើនការទទួលស្គាល់ជាផ្លូវការនូវសិទ្ធិរបស់ជនក្រីក្រក្នុងការតាំងទីលំនៅក្នុងតំបន់ទីក្រុង។ ប្រសិនបើអាចបញ្ចុះបញ្ចូលរដ្ឋាភិបាល និងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត ឲ្យយល់ពីតម្រូវការអន្តរាគមន៍គាំទ្រដល់ជនក្រីក្រនោះ ខាងផ្នែកគោលនយោបាយ ក៏នឹងដើរតាមនោះដែរ។

ការអភិវឌ្ឍទីក្រុងសម្រាប់គ្រប់គ្នា មិនត្រឹមតែជាកាតព្វកិច្ចផ្នែកសីលធម៌ប៉ុណ្ណោះទេ វាក៏ជាបុព្វលក្ខខណ្ឌសម្រាប់នគរូបនីយកម្មមានចីរភាពល្អដែរ ទាំងផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច។ ឧទាហរណ៍ Ha (2001) បានកត់សម្គាល់ថា នៅទសវត្សរ៍១៩៧០ គោលនយោបាយអាជ្ញាធរក្រុងសេអ៊ូល គឺ ការផាត់ជនក្រីក្រចេញពីទីក្រុង ទៅកាន់តំបន់ជាយក្រុង។ ក្នុងការស្វែងរកឱកាសចិញ្ចឹមជីវិត គ្រួសារក្រីក្រនានា ក៏តាំងលំនៅបែបអនាធិបតេយ្យជាថ្មីនៅក្នុងទីក្រុង ដែលជារឿយៗមានស្ថានភាពកាន់តែយ៉ាប់យ៉ឺនជាងមុនទៀត។ ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋបានបង្កើតក្របខ័ណ្ឌគម្រោងអភិវឌ្ឍន៍ឡើងវិញរួមគ្នា ដែលជួយសម្រួលដល់កិច្ចសហការជាដៃគូរវាង សហគមន៍ក្រីក្រនៅទីក្រុង និងវិស័យឯកជន ដើម្បីអភិវឌ្ឍឡើងវិញនូវតំបន់អនាធិបតេយ្យ។ ក្របខ័ណ្ឌនេះបានវិវត្តទៅមុខ ហើយទោះបីមានការមិនឯកភាពគ្នាខ្លះអំពីជោគជ័យក្នុងបញ្ហានេះក្តី (e.g. Shin 2008) ក៏គោលនយោបាយសម្រាប់ការស្នាក់នៅរយៈពេលវែង ពិតជាបានផ្លាស់ប្តូរពីការផាត់ចេញ ទៅជាការរាប់បញ្ចូលវិញ ហើយបានជះឥទ្ធិពលល្អទៅលើគន្លងនៃការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចនៅទីក្រុង។ ក្នុងអំឡុងពីរបីទសវត្សរ៍ចុងក្រោយនេះ គោលនយោបាយរដ្ឋាភិបាលកម្ពុជា មានលក្ខណៈដូចគ្នានឹងគោលនយោបាយក្រុងសេអ៊ូលនៅទសវត្សរ៍១៩៧០ ដែរ៖ ការបណ្តេញចេញ ជាគោលនយោបាយសម្រាប់ដោះស្រាយជាទូទៅ ចំពោះការតាំងលំនៅមិនផ្លូវការ ហើយគ្រួសារជាច្រើនបានផ្លាស់ទីពីតំបន់ជាយៗនោះចូលមកក្នុងទីក្រុងវិញ (Khemro & Payne 2004)។ ប៉ុន្តែនាពេលថ្មីៗនេះ មានករណីជាច្រើនដែលរដ្ឋាភិបាលបានជួយសម្រួលការកែលំអតំបន់ តាមការលើកទឹកចិត្តឲ្យសហគមន៍ ចូលពាក់ព័ន្ធជាមួយនឹងវិស័យឯកជន។ ឧទាហរណ៍ សម្រាប់សហគមន៍នៅបុរីកីឡា ដំណោះស្រាយធ្វើការអភិវឌ្ឍឡើងវិញ ដោយមានការបែងចែកដីគ្នា និងការចូលរួមជាដៃគូជាមួយវិស័យឯកជន បាននាំឲ្យមានការសាងសង់នូវប្លុកផ្ទះល្វែង ផ្តល់ទៅឲ្យគ្រួសារដែលរស់នៅកន្លែងនោះ ហើយយកដីដែលនៅសល់ ទុកសម្រាប់ប្រើការផ្សេងទៀត។ ការអនុវត្តគម្រោងនេះ បានជួបបញ្ហាធ្ងន់ធ្ងរជាច្រើន ប៉ុន្តែយ៉ាងហោចណាស់ក៏ជាសញ្ញាបង្ហាញថា រដ្ឋាភិបាលបានផ្លាស់ប្តូរវិធីសាស្ត្រ និងមានបំណងដាក់បញ្ចូលអ្នកដែលកំពុងរស់នៅទីនោះ ទៅក្នុងគម្រោងអភិវឌ្ឍន៍នាថ្ងៃអនាគត៖ គំរូនេះ គួរត្រូវចម្លងតាម និងពង្រឹងបន្ថែមទៅថ្ងៃខាងមុខ។

នៅមានផលចំណេញខាងសេដ្ឋកិច្ចជាច្រើនទៀត ក្នុងការរាប់បញ្ចូលជនក្រីក្រនៅទីក្រុងនេះ៖ សេដ្ឋកិច្ចមិនផ្លូវការ អាចជាប្រភពចំណូលរដ្ឋាភិបាល និងជាប្រភពកំណើនសេដ្ឋកិច្ចមានសក្តានុពលធំធេងតែមិនទាន់ប្រើការ។ De Soto (2000) បានអះអាងថា នាបច្ចុប្បន្ន ប្រាក់រាប់ពាន់លានដុល្លារ កំពុងដេកស្ងៀមដូច "មូលធនងាប់" នៅក្នុងសេដ្ឋកិច្ចមិនផ្លូវការរបស់ប្រទេសកំពុងអភិវឌ្ឍ។ Beall and Fox (2009) បានលើកថា វិស័យមិនផ្លូវការនៅកម្ពុជាមានទំហំធំ ដោយសារមានបែបបទការិយាធិបតេយ្យច្រើនរារាំងបុគ្គលនានា នៅក្នុងវិស័យមិនផ្លូវការក្នុងការចុះបញ្ជីអាជីវកម្មរបស់ខ្លួនជាផ្លូវការ ឲ្យក្លាយទៅជាអាជីវកម្មស្របច្បាប់ ហើយចាកផុតពីស្ថានភាពមិនផ្លូវការនេះ ដែលនាំឲ្យមានបន្ទុកចំណាយខ្ពស់ និងជួបហានិភ័យច្រើន។ ការលុបបំបាត់ឧបសគ្គទាំងនេះ អាចជួយជំរុញគំនិតច្នៃប្រឌិតសហគ្រិនភាព កំណើនសេដ្ឋកិច្ចសម្រាប់គ្រប់គ្នា ព្រមទាំងផ្តល់ឲ្យរដ្ឋាភិបាលនូវចំណូលជាច្រើនទៀត សម្រាប់ដោះស្រាយតម្រូវការបង្កើនចំណាយសាធារណៈ។

## ការធ្វើផែនការសម្រាប់អនាគត - តម្រូវការរបៀបវារៈស្រាវជ្រាវពីទីក្រុង

នគរូបនីយកម្ម ជាទិដ្ឋភាពមួយនៃការអភិវឌ្ឍនៅកម្ពុជា ដែលមានការស្រាវជ្រាវតិចតួចណាស់។ ភាគច្រើននៃរបៀបវារៈស្រាវជ្រាវ បានផ្តោតលើវិស័យកសិកម្ម ដែលតាំងពីដើមរៀងមក គេតែងយល់ថា វាសំខាន់បំផុតសម្រាប់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រទៅថ្ងៃអនាគត។ ការពិនិត្យត្រួសៗទៅលើផលិតផលរបស់ស្ថាប័នស្រាវជ្រាវធំៗនៅកម្ពុជា របៀបវារៈសន្និសីទ និងការបោះពុម្ពផ្សាយរបស់ដៃគូអភិវឌ្ឍន៍ បានបង្ហាញពីភាពលំអៀងខ្លាំងទាក់ទងនឹងការស្រាវជ្រាវនេះ។ របៀបវារៈស្រាវជ្រាវផ្តោតលើទីជនបទ វាផុសចេញមួយផ្នែកពីរចនាសម្ព័ន្ធផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ និងតំណាងឲ្យមនោគមវិជ្ជាបន្សល់ទុកពីសម័យសេរីនិយមបែបថ្មី ជាពិសេសទ្រឹស្តី "លំអៀងទីក្រុង (urban bias)" ដែលពេញនិយមនៅពេលនោះ និងលំអៀងទៅខាងអន្តរាគមន៍គោលនយោបាយនៅជនបទ ជាជាងនៅទីក្រុង។ ដោយពិភពលោកបានឈានចូលក្នុងសតវត្សរ៍នគររូបនីយកម្ម ដូច្នេះត្រូវតែទទួលស្គាល់ពីតួនាទីដ៏សំខាន់បំផុតនៃតំបន់ទីក្រុងក្នុងដំណើរការអភិវឌ្ឍន៍។

របៀបវារៈស្រាវជ្រាវពីទីក្រុង ក៏ជួបឧបសគ្គដែរ ដោយសារការជជែកវែកញែកពីរបៀបវារៈនេះ ត្រូវជួបរហូតនឹងបញ្ហាសិទ្ធិ

កាន់កាប់ដីធ្លីដែលអង្គការសិទ្ធិមនុស្ស តែងលើកឡើងតទល់នឹងរដ្ឋ។ ជាលទ្ធផល កិច្ចសន្ទនាពីការអភិវឌ្ឍទីក្រុងបានបង្កជាការបែងចែកជាបក្សពួក ភាគច្រើនគ្រាន់តែជាការនិយាយយកឈ្នះ ហើយអាចរួមចុះមកផ្តោតតែលើបញ្ហាមួយនៃការជជែកវែកញែកពីសិទ្ធិមនុស្ស និងមានឥទ្ធិពលតិចតួចខាងគោលនយោបាយ។ កិច្ចសន្ទនាមានកម្រិតបែបនេះ មិនអំណោយផលដល់របៀបវារៈស្រាវជ្រាវរស់រវើក ដែលអាចរកឃើញបញ្ហាច្រើនបែបយ៉ាង និងផ្តល់មតិពីដំណោះស្រាយផ្សេងៗខាងគោលនយោបាយនោះទេ។ ម្យ៉ាងទៀត ទោះបីការសន្ទនារវាង NGOs ខាងសិទ្ធិមនុស្ស និងរដ្ឋ គឺជាយន្តការដ៏សំខាន់សម្រាប់លើកស្ទួយសិទ្ធិរបស់ជនក្រីក្រនៅទីក្រុងក្តី ក៏វាមិនគួររារាំង NGOs ជាច្រើនទៀត ក្នុងការចូលរួមជាមួយរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាផ្សេងទៀត ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍទីក្រុងសម្រាប់គ្រប់គ្នានោះទេ។ Phonphakdee *et al.* (2009: 579) បានគូសបញ្ជាក់ពីបញ្ហាប្រឈមរបស់អង្គការ ដូចជា UPDF ជាដើម ដែលព្យាយាមចូលរួមធ្វើការជាមួយរដ្ឋ ដោយកត់សម្គាល់ថា "គោលគំនិតចូលរួមធ្វើការជាមួយរដ្ឋាភិបាលនេះ មិនងាយទទួលយកបានទេ សម្រាប់សកម្មជន ឬ NGO ជាច្រើន ដែលតែងយល់ឃើញជាយូរមកហើយថា រដ្ឋាភិបាលជាភាគីមិនល្អនោះ"។ ទោះយ៉ាងនេះក្តី វិធីសាស្ត្រធ្វើការរួមគ្នាលើបញ្ហាភាពក្រីក្រនៅទីក្រុងនេះ ពិតជាសំខាន់បំផុត ដើម្បីលើកកម្ពស់ការយល់ដឹងពីតំបន់ទីក្រុងនៅកម្ពុជា និងកែលំអជីវភាពជនក្រីក្រនៅទីក្រុង។

ទាក់ទងនឹងអាទិភាព ខាងគោលនយោបាយទីក្រុងវិញ ក្នុងវិធានការរយៈពេលខ្លី ដោយពុំមានកម្មវិធីប្រព័ន្ធសុវត្ថិភាពសង្គមសម្រាប់គ្រួសារក្រីក្រនៅទីក្រុង ដែលឧបត្ថម្ភដោយរដ្ឋនោះ រដ្ឋាភិបាល គួរផ្តល់ការគាំទ្របន្ថែមទៀតដល់ក្រុមសង្គមស៊ីវិល ដូចជា UPDF ជាដើម។ នៅក្នុងរយៈពេលមធ្យម ទៅរយៈពេលវែង ក្របខ័ណ្ឌសកម្មភាពផ្តួចផ្តើមឡើងដោយ UPDF អាចផ្តល់ជាមេរៀន និងយន្តការសំខាន់ៗសម្រាប់សកម្មភាពរបស់រដ្ឋទៅអនាគត។ ការតភ្ជាប់រវាងសហគមន៍ និងរដ្ឋាភិបាល ផ្តល់នូវច្រកទាក់ទងផ្តល់ព័ត៌មានដ៏មានប្រយោជន៍មួយរវាង តម្រូវការនៃពួកគ្រួសារក្រីក្រនៅទីក្រុង និងអ្នកធ្វើគោលនយោបាយ។ វាក៏ជួយកាត់បន្ថយចំណាយប្រតិបត្តិការ ដោយធានាថាអន្តរាគមន៍គោលនយោបាយទៅថ្ងៃអនាគត ពិតជាស្របតាមការពិតជាក់ស្តែង។ ការតភ្ជាប់នេះ អាចបង្កើនឥទ្ធិពលនៃគោលនយោបាយគាំទ្រជនក្រីក្រទៅថ្ងៃអនាគត បានយ៉ាងច្រើន។ ដោយមើលឲ្យហួសពីភាពក្រីក្រនៅទីក្រុង ដែលមានច្រើនពាសពេញនេះ រដ្ឋាភិបាលគួរផ្តោតកម្លាំងលើការពង្រឹងហេដ្ឋារចនាសម្ព័ន្ធរឹង និងទន់ ដើម្បីអាចជួយសម្រួលវិនិយោគ និងពាណិជ្ជកម្មក្នុងតំបន់បានកាន់តែប្រសើរ។ គោលដៅនេះមានលក្ខណៈពាក់ព័ន្ធល្អ ជាពិសេសក្នុងឆ្នាំនេះ ដែលប្រទេសកម្ពុជាកំពុងទទួលវេណធ្វើជាប្រធានអាស៊ាន។ បញ្ហាជាទូទៅនៅពេលនេះ គឺ ការពង្រឹងសមត្ថភាពស្ថាប័នដើម្បីអនុវត្តគោលនយោបាយមានស្រាប់ ដែលលើកទឹកចិត្តដល់ពិពិធកម្មវិនិយោគ និងពាណិជ្ជកម្មនៅទីក្រុង។ ដូច្នេះ បណ្តាញស្ថាប័នស្រាវជ្រាវនៅកម្ពុជា ត្រូវតែជំរុញរបៀបវារៈស្រាវជ្រាវសព្វគ្រប់ និងមានតុល្យភាពល្អមួយពីទីក្រុង ហើយតាមនេះ អាចជួយដល់រដ្ឋាភិបាល ក្នុងការជំរុញឲ្យមានការរីកចម្រើនទីក្រុងប្រកបដោយចីរភាព និងសម្រាប់គ្រប់គ្នា។

## ឯកសារយោង


Beall, J. & S. Fox (2009), *Cities and Development* (London: Routledge)

De Soto (2000), *The Mystery of Capital: Why Capitalism Triumphs in the West and Fails Everywhere Else* (New York: Basic Books)

Ear, S. (1995), *Cambodia's Economic Development in Historical Perspective: A Contribution to the Study of Cambodia's Economy,* available at: http://www.csua.berkeley.edu/~sophal/econ.pdf (accessed 4 June 2012)

Ha, S.K. (2001), "Developing a community-based approach to urban redevelopment", *GeoJournal*, Vol. 53, pp. 39-45

Harvey, D. (2004), *The Condition of Postmodernity: An Inquiry into the Origins of Cultural Change* (Oxford: Blackwell)

Helmers, K. (1997), "Rice in the Cambodian Economy: Past and Present", in H.J. Nesbitt (ed.), *Rice Production in Cambodia* (Manila: IRRI) pp. 1-14

Khemro, B.H.S. & G. Payne (2004),"Improving tenure security for the urban poor in Phnom Penh, Cambodia: an analytical case study", *Habitat International*, Vol. 28, No. 2, pp. 181-201

Mitlin, D., D. Satterthwaite & S. Barlett (2011), *Capital, Capacities and Collaboration: The Multiple Roles of Community Savings in Addressing Urban Poverty,* International Institute for Economic Development Human Settlements Working Paper (London: IIED)

Moore, M. & J. Putzel (1999), *Thinking Strategically about Politics and Poverty,* Institute of Development Studies Working Paper 101 (Brighton: IDS)

Phonphakdee, S., S. Visal & G. Sauter (2009), "The Urban Poor Development Fund in Cambodia: supporting local and citywide development", *Environment and Urbanization,* Vol. 21, No. 2, pp. 569-586

Royal Government of Cambodia (2002), *National Poverty Reduction Strategy Paper 2003-2005* (Phnom Penh: RGC)

Shin, H.B. (2008), "Living on the edge: financing post-displacement housing in urban redevelopment projects in Seoul", *Environment and Urbanization,* Vol. 20, No. 2, pp. 411-426

UN-HABITAT (2008), *State of the World's Cities 2010/2011: Bridging the Urban Divide* (London: Earthscan)

World Bank (2012), World Development Indicators (WDI) [online], available at: http://databank.worldbank.org/ddp/home.do (accessed 4 June 2012)